# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៥៦

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់សាក្សីចុងក្រោយចំនួនពីររូបលើប្រធានបទមន្ទីរសន្តិសុខ ស-២១ ក្នុងទីក្រុងភ្នំពេញ។ សាក្សីដំបូងគេ គឺលោក **សួស ធី** បានបញ្ចប់ការផ្តល់សក្ខីកម្មរបស់គាត់ដែលបានបន្តកាលពីសប្តាហ៍មុន ស្តីពីតួនាទីរបស់គាត់ជាអ្នកកាន់បញ្ជីអ្នកទោសនៅ ស-២១។ នៅថ្ងៃអង្គារមុននឹងឈប់សម្រាកអាហារថ្ងៃត្រង់បន្តិច សក្ខីកម្មរបស់សាក្សីលោក **សួស ធី** បានមកដល់ទីបញ្ចប់ ហើយអង្គជំនុំជម្រះបានស្តាប់ការធ្វើសម្បថរបស់សាក្សីលោក **កាំង ហ្គេកអ៊ាវ** ដែលជាទូទៅត្រូវបានគេស្គាល់ឈ្មោះបដិវត្តន៍របស់គាត់ ដែលមានរហស្សនាមថា "ឌុច"។ ឌុច ធ្លាប់បានបម្រើការងារជាអនុប្រធាន និងក្រោយមកបានក្លាយជាប្រធានមន្ទីរសន្តិសុខ ស-២១ (សំដៅលើ គុកទួលស្លែង) ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយគាត់ក៏ធ្លាប់ត្រូវបានតុលាការធ្វើការជំនុំជម្រះក្តី និងបានផ្តន្ទាទោសនៅក្នុងសំណុំរឿងលេខ០០១ អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ផងដែរ។[1] នៅខណៈពេល

[1] លោក **កាំង ហ្គេកអ៊ាវ** (ហៅ ឌុច) ត្រូវបានរកឃើញដោយអង្គជំនុំជម្រះសាលាដំបូង ថាមានពិរុទ្ធភាព និងត្រូវបានកាត់ទោស ឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, សូមមើល "សាលក្រម" របស់អង្គជំនុំជម្រះសាលាដំបូង (ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០) លេខ E188។ លោក **កាំង ហ្គេកអ៊ាវ** បានប្តឹងសាទុក្ខនឹងសាលក្រមនេះទៅអង្គជំនុំជម្រះតុលាការកំពូល តែត្រូវបានបដិសេធចោល។ រីឯការិយាល័យសហព្រះរាជអាជ្ញា ក៏បានប្តឹងសាទុក្ខលើសាលក្រមនេះផងដែរ ហើយនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងបានបង្កើនរយៈពេលជាប់ពន្ធនាគារអស់មួយជីវិតដល់ជនជាប់ចោទនេះផងដែរ, សូមមើល "សាលដីកាលើបណ្តឹងសាទុក្ខ" របស់អង្គជំនុំជម្រះតុលាការកំពូល (ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២) លេខ F28។

ដែលកំពុងអនុវត្តទោសជាប់ពន្ធនាគារអស់មួយជីវិតរបស់ខ្លួន សាក្សី ឌុច បានបង្ហាញខ្លួនក្នុងតុលាការ នាសប្តាហ៍នេះ ដើម្បីផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២ វគ្គ២ ស្តីពីការយល់ដឹងរបស់គាត់អំពីឋានានុក្រម គោលនយោបាយ និងសកម្មភាពនានារបស់បក្សកុំម្មុយនីស្តកម្ពុជា។[2] សាក្សី ឌុច គ្រោងនឹងផ្តល់សក្ខីកម្មរយៈពេលចំនួនប្រាំបួនថ្ងៃពេញ ដែលបួនថ្ងៃសម្រាប់សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បួនថ្ងៃទៀតសម្រាប់ក្រុមសហមេធាវីការពារក្តីទាំងពីរ និងមួយថ្ងៃសម្រាប់ចៅក្រម ដើម្បីធ្វើការសាកសួរដេញដោល។ នាសប្តាហ៍នេះ ក្រុមសហព្រះរាជអាជ្ញា ដែលដឹកនាំដោយជំនួយការសហព្រះរាជអាជ្ញា គឺលោក **ឌែល លីសាក់** (**Dale Lysak**) និងសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រី **ម៉ារី ហ្គីរ៉ូឌ** (**Marie Guiraud**) បានតាំងសំណួរដេញដោលទៅកាន់ **ឌុច** ស្តីពីតួនាទីរបស់ជនជាប់ចោទលោក **នួន ជា** នៅមន្ទីរសន្តិសុខ ស-២១ ការប្រព្រឹត្តទៅលើទាហាន **លន់ នល់** អំពើហិង្សាលើផ្លូវភេទ និងទម្រង់ផ្សេងៗនៃការធ្វើទារុណ្ណកម្មអ្នកទោស។ សាក្សី **ឌុច** នឹងបន្តផ្តល់សក្ខីកម្មរបស់គាត់នៅសប្តាហ៍ក្រោយ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ លេណា ហារីស-ផមមើរ៉យ (Lena Harris-Pomeroy), ខេតលីន កាហ្វប្រៀ (Caitlin McCaffrie), នំ វិសុទ្ធ, តាយ លីណា និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

---

2 លោក **កាំង ហ្គេចអ៊ាវ** បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២ វគ្គ១ ដោយប្រើប្រាស់រយៈពេលអស់ ១២ថ្ងៃពេញ ចាប់តាំងពីថ្ងៃទី១៩ មីនា ដល់ ទី១០ ខែមេសា ឆ្នាំ២០១២។ សម្រាប់សេចក្តីសង្ខេបស្តីពីសក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង០០២ វគ្គ១ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម ក្នុងសំណុំរឿង០០២ លេខ១៥ ស្តីពីសវនាការលើកស្តុតាង សប្តាហ៍ទី១០ (ចុះថ្ងៃទី១៩-២១ ខែមីនា ឆ្នាំ២០១២), របាយការណ៍លេខ១៦ ស្តីពីសវនាការលើកស្តុតាង សប្តាហ៍ទី១១ (ចុះថ្ងៃទី២៦-២៩ ខែមីនា ឆ្នាំ២០១២), របាយការណ៍លេខ១៧ ស្តីពីសវនាការលើកស្តុតាង សប្តាហ៍ទី១២ (ចុះថ្ងៃទី២-៥ ខែមេសា ឆ្នាំ២០១២), របាយការណ៍លេខ១៨ ស្តីពីសវនាការលើកស្តុតាង សប្តាហ៍ទី១៣ (ចុះថ្ងៃទី៩-១០ ខែមេសា ឆ្នាំ២០១២)។